ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមហ៊ុន វី.ស៊ី.អូ.អេហ្វ.អេហ្វ អាប៉ារ៉ែល ខូ.អិលធីឌី**
V.C.O.F.F APPAREL CO.,LTD
ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ
Phum Domnak Trayeoung, Sangkat Chaomchav, Khan Por Senchey,
Phnom Penh, Cambodia

**ក.ព.៧/ ការិយាល័យរដ្ឋបាល**
**លេខ: ០០៧/២០**

**កិច្ចព្រមព្រៀង**
**រវាង**
**ក្រុមហ៊ុន វី.ស៊ី.អូ.អេហ្វ.អេហ្វ អាប៉ារ៉ែល ខូ.អិលធីឌី**
**និង**
**តំណាងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន វី.ស៊ី.អូ.អេហ្វ.អេហ្វ អាប៉ារ៉ែល ខូ.អិលធីឌី**
**ស្តីអំពីការព្យួរការងារ**

នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង០៨និង០០នាទី នៅក្នុងក្រុមហ៊ុន *វី.ស៊ី.អូ.អេហ្វ.អេហ្វ អាប៉ារ៉ែល ខូ.អិលធីឌី* មានកិច្ចប្រជុំមួយ រវាង តំណាងក្រុមហ៊ុន និង សហជីព តំណាងកម្មករប្រចាំក្រុមហ៊ុន ។

នៅក្នុងអង្គប្រជុំនេះនាយកក្រុមហ៊ុន បានជូនដំណឹងដល់បងប្អូនកម្មករ កម្មការិនីទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរោងចក្រថាពេលនេះ រោងចក្រមិនមានការបញ្ជាទិញគ្រប់គ្រាន់ ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូល ដំណើរការបានហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់បងប្អូនកម្មករកម្មការិនី ចំនួន០២ខែ ចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ទៅដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ដោយយោងទៅតាម សេចក្តីណែនាំលេខ០៤៥/២០ ស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ បងប្អូនកម្មករកម្មការិនីបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុនដូចខាងក្រោម៖

១-ក្រុមហ៊ុនផ្តល់ ប្រាក់ឈ្នួលក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារចំនួន ៣០ដុល្លា (សាមសិបដុល្លាអាមេរិកគត់) នៃប្រាក់ឈ្នួល គោលអប្បបរមា ១៩០ដុល្លា ក្នុងឆ្នាំ២០២០ រៀងរាល់ថ្ងៃទី១០ នៃខែបន្ទាប់។

២-ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងផ្តល់ប្រាក់បន្ថែមចំនួន ៤០ដុល្លា (សាមសិបដុល្លាអាមេរិកគត់) នៃប្រាក់ឈ្នួល គោលអប្បបរមា ១៩០ដុល្លា ក្នុងឆ្នាំ២០២០។

៣- ក្នុងករណីក្រុមហ៊ុនមានការបញ្ជារទិញវិញ កម្មករ-និយោជិត អាចចូលធ្វើការមុនកាលកំណត់ ដែលគិតប្រាក់ឈ្នួលតាមចំនួនថ្ងៃធ្វើការជាក់ស្តែង។

៤-កម្មករកម្មការិនី ត្រូវចូលធ្វើការងារជាធម្មតាវិញ **ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០**។ ក្នុងករណីបងប្អូនកម្មករកម្មការិនីដែលមិនបានចូលធ្វើការតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តន៏តាមច្បាប់ស្តីពីការងារ និង បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

អង្គប្រជុំបានចប់វេលាម៉ោង០៤និង៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទូល និង សហការគ្នាយ៉ាងរលូន។

**បញ្ជាក់:** កិច្ចព្រមព្រៀងនេះ មានប្រសិទ្ធិភាពចំពោះ កម្មករ-និយោជិតទាំងអស់របស់រោងចក្រ *ភី.ស៊ី.អេហ្វ.អេហ្វ អ៊ីភែរឹល ឯ.ក* ជាមួយនឹងនិយោជកនៃរោងចក្រ *ភី.ស៊ី.អេហ្វ.អេហ្វ អ៊ីភែរឹល ឯ.ក* ។

ភ្នំពេញ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

នាយក្រុមហ៊ុន

**តាំង ម៉េង**

**ឈ្មោះ និងស្នាមមេដៃស្ដាំរបស់ តំណាងកម្មករ-និយោជិត**